ម្ដាយ ស្គាល់ចូលចិត្តថាមិនសម្រេចប្រយោជន៍មែន ទើបថែមសួរថា „ឯងចូលទៅដេកស្លៀកពាក់យ៉ាំងម្ដេច,,

កូន ថា „ចាស អ៊ីចឹង-,

ម្ដាយ „ម្ដាយគក់ទ្រូង ហើយថាកូនឯងល្ងង់អីម្ល៉េះ

កូនថា „ចេះយ៉ាំងម្ដេចទៅម៉ែ ,,

ម្ដាយ ថា " គេដែលចេះនោះ គេមិនមែន ទៅដេកស្កូកស្ដឹង សឹងតែមិនកម្រើកដៃជើងនោះទេ គេត្រូវផ្លាស់សំពត់ដោះអាវក្រៅ ទុកតែអាវទ្រនាប់ស្ដើង ដៃជើងគេត្រូវតែសកេះនាយកេះអាយ ឲ្យគេក្រឡេកឃើញរូបកាយនេះនោះទៅខ្លះ នេះហើយជាគ្រឿងគៀនដាស់ ដើម្បីបងចិត្តឲ្យប្រុសប្រតិព័ទ្ធនិត្យនៅ ទើបគេហៅថាស្រីមានប្រាជ្ញា ម៉ែតាំងចិត្តថា នឹងជួយឲ្យកូនឯងបានសម្រេចប្រយោជន៍ទៅថ្ងៃមុខពុំឆ្ងាយ ទើបម៉ែមិនស្ដាយកេរ្តិ៍ ដូចលោកមាឯងតាំងពីរ គេក៏បានឲ្យន័យពីថ្ងៃម្សិល



មិញស្រាប់ កូនឯងក៏បានឮស្ដាប់ជម្រួយទៅដែរ ម៉េចឯងមិនជួយបំពេញកំឡាំងម៉ែ ដែលម៉ែប្រាថ្នា ឯងធ្វើមិនឲ្យបានការដូច្នេះ យើងនឹងសង្ឃឹមសំណាងព្រេងកើតឡើងពីនៅឯណា ?„

កូន ឆ្លើយថា យីម៉ែអើយម៉ែគួរប្រដៅរំលឹកខ្ញុំឲ្យចេះខាងដំរះវិជ្ជាតាមប្រសាស្រី ឲ្យរៀនត្បាញរវៃលើកផ្កាព្រហូលឲ្យយល់គោមគាក ទើបខ្ញុំនឹងទំបង្អាកយកចិត្តទុកដាក់មិននឹកពុញទ្រាន់ ដែលម៉ែនឹងឲ្យខ្ញុំទៅប្រយ័ក ប្រទាញប្រុសឲ្យគេមកចុះត្រូវការនឹងខ្លួន នោះកូននឹងខ្លួនអៀនខ្មាសគេណាស់ សុំកុំបានប្រសាសន៍នេះជាកំពូលគាប់ប្រសើរណាស់ ព្រោះខ្ញុំមិនទាន់ចេញក្បាច់នោះ បើខ្ញុំទៅធ្វើឲ្យផ្លាស់ដូចប្រសាសន៍ ហើយគេនៅតែមិនលែងទៀត ខ្ញុំនិងរឹតតែអៀនខ្មាសទៅទេឬ ខ្ញុំដូចជាចង់បន្ទោសម៉ែ មិនគួរគិតការរួសរាន់ពេកថ្លៃកពីគេ

ធម្មតា ចាស់តែខ្វះការឲ្យគេហ៊ានទិញបាន ម្ដេចក៏ម៉ែមិនធ្វើតាមបុរាណគេមកដណ្ដឹងរៀបការទំនៀមចាស់ៗ

ម្ដាយថា "ឯងបន្ទោសម៉ែត្រូវណាស់ តែម៉ែជាចាស់គិតវែងឆ្ងាយ ប្រៀបដូចយើងដើរកកាយរកត្បូងពេជ្រដ៏មានដំឡៃ ហើយយើងក្រឡេកទៅឃើញស្មៅពេជ្រ ដុះនៅកណ្ដាលអន្ទង់លាមកពេញជុំវិញ បើយើងចង់បានពេជ្រជាទីស្រឡាញ់ ត្រូវតែលុយអន្ទង់លាមកនោះទៅយកមុនគេឲ្យបាន ពោះលាមកនឹងប្រឡាក់ខ្លួនប្រាណយ៉ាងណាក៏តាមការចុះ យើងមិនបោះកេសាប៉ុះជាក្រោយទេ" ឯរឿងនេះក៏នឹងពោលមកប្រាប់ មុនអ្នកនេះមក១យប់ ម៉ែយល់សប្តិឃើញហ្លួងជាម្ចាស់ផែនដីកាន់ទង់ជ័យមាស១មកឲ្យម៉ែ ហ្លួងប្រាប់ថា ទង់ជ័យស្ដេចនៃខ្លួនពូកែណាស់ ឈ្នះសត្រូវគ្រប់ទិស សូម្បីខ្មោចសាចសាបព្រាយក៏ខ្លាច ទង់ជ័យនេះ ត្រូវនាងឯងយ



ទៅឲ្យកូនស្រី ដែលឈើនោះចុះ ជាកេរ្តិ៍សម្រាប់របស់វាហើយ បើបានកាន់ក្ដី ដូចទង់ជ័យបក់មកត្រូវខ្លួនវាក្ដីនឹងជាជម្នះ តែត្រូវប្រយ័ត្នកុំឲ្យអ្នកណាដណ្ដើមបាន ម៉ែក៏បានឲ្យទង់ជ័យទៅឯងៗ យកទៅម៉ែអរណាស់ណាកូនព្រោះម៉ែទើបគិតទៅឃើញត្រូវចាំងរស់ត្រសុវណ្ណ ទង់ជ័យមាសគេមកកាន់ខ្លួនឯងតែ១ចុះ ជម្នឹងឯងក៏ជាមួយរំពេច អ្នកនេះនៅខែត្រចន្ទាយមាស មាសក៏សុវណ្ណៗក៏មាស ឯងឃើញត្រូវដែរទេ?

កូន "ត្រូវហើយម៉ែ"

ម្ដាយ "ហ្នឹងហើយឯងមិនត្រូវបន្ទោសម៉ែសោះ ថ្វីម៉ែធ្វើខុសចាស់ទិនអ្នកស្រុកជុំ ទោះនរណាគេសើចយំរលើងដុះក៏តាមការចុះ ឯងនិយាយប្រាប់ម៉ែឲ្យគ្រន់ទៅកុំខ្មាសអៀនអី ឯងនឹងគេប្រាកដជាគ្មានប៉ះពាល់អ្វីមែនឬ?

កូនថា "ចាស គ្មានទេលើសស្អាត ប៉ុន្តែខ្ញុំបាន

និយាយនឹងគេបានសេចក្តីហើយកុំឲ្យម៉ែព្រួយឲ្យសោះ អ្នកនេះប្រាកដជាមនុស្សគ្រន់អត្ថីក្នុងកាយ គេលើកយកក្តាយជាទីគោរពមុន ព្រោះគេជាអ្នកដឹងគុណមាតាបីតា តែខ្ញុំប្រមាណថាគេគ្រាន់តែធ្វើគំរប់ការទេ គេក៏បានឲ្យចិញ្ចៀនត្បូងកណ្តៀង១មកខ្ញុំតំណាងឲ្យជឿ ខ្ញុំបានឲ្យសង្វារ១ខ្សែទៅវិញតំណាងគ្នា នាងក៏លើកចិញ្ចៀនបង្ហាញមាតា ៗ មាតាឮដូច្នេះក៏អស់សេចក្តីតែក្ត មានទឹកមុខរីករាយប៉ែបសប្បាយចិត្តណាស់ ដើរពីផ្ទះបាយមកផ្ទះធំទទួលហ្វូងសក្តាចេញពីក្នុងមកហ្វូងសក្តា ទឹកនឹងខ្លួនពេកណាស់ ព្រោះស្រីនិស្រា ឲ្យគេលើកយួរតាត្តាទៅដាក់ផ្ទុក ដូចគេដោះបាយបញ្ចោសម្រេចឲ្យថ្ពែក ប៉ុន្តែជាសេចក្តីតាំប៉ុនមិនធ្វើឲ្យលើខុសហ្វូងសក្តាក៏លុកជង្គង់ចុះ សំពះនាងម៉ារិន ហើយនិយាយថា ៈខ្ញុំបាទសុំទោស អ្នកជាមាតាកុំឲ្យប្រកាន់ ព្រោះមុនដែលខ្ញុំបាទនឹងផ្អែកអាហារពីល្ងាចមិញ ខ្ញុំបាទ



ទឹកក្នុងចិត្តថា ព្រឹកនេះនឹងវិលទៅខ្ញែគ្រប់ត្នាយមាស ដើម្បីនឹងដាក់បង្អកម្តាយខ្ញុំបាទ ឲ្យចូលមកជណ្តើងរៀបការអ្នកម្ដូននឹងខ្ញុំបាទ ឲ្យត្រឹមត្រូវតាមទំនៀមទម្លាប់ តែខ្ញុំបាទបានកម្មអកត្តញ្ញូនឹងដឹងទៅបមាតា នឹងព្រះរាជកុមារលោកបានទុក្ខ ដូចធ្លាក់ពីចុងឈើ ស្តាប់ខ្លួនហេតុនេះខ្ញុំបាទសូមក្រាបប្រណិប័តន៍លាអ្នកមាតា នឹងអ្នកម្ដូន ទៅជួយដោះទុក្ខលោកសិន មិនដឹងជាយ៉ាងណាទេ ការចិត្តដែលខ្ញុំបាទឈឺ ស្មើនឹងកាន់ដាវទៅកាត់ក្បាលមនុស្សសត្រូវវង្សហ្នឹង ខ្ញុំបាទគ្មានខាចបន្តិចសោះ

វេលានោះទទួលម្ចាស់ផ្ទះសំណាក់មកជួបជុំគ្នា បានឃើញហ្វូងសក្តានឹងដូច្នេះក៏ជួយលើកហាមប្រាមគេបងមិនឲ្យប្រើប្រាជ្ញាដោះទៅបមាតា ហើយយាត់ឲ្យនៅពិសាបាយព្រឹក ហ្វូងសក្តាអង្វរមិនព្រម នៅទទួលទានអាហារ ហើយនិយាយថា៖ ខ្ញុំបាទសូមប្រណិប័តន៍មាតា

សន្យានឹងអូនពីរឿងកិច្ចផ្ដាល់ខ្លួននោះ ខ្ញុំបាទនឹងសន្ទត់ខ
ថ្ងៃទៀត ជានឹងមកសំរេចការនោះ វេលាណាពុំបាន
ទេ ព្រោះខ្លួនមិនទាន់ដោយការសង្គ្រាម សូមមាតា
នឹងអ្នកប្អូនគិតបំភ្លេចឈ្មោះនិងរូបកាយ ខ្ញុំបាទឲ្យបាត់ទៅ
សិនចុះ" ជាហើយក៏យំស្រក់ទឹកនេត្រា នាងម៉ានៃ
នឹងបងស្រី ហើយនឹងនាង គិន-យ៉ាន់ ក៏យំសោកតាំង
អស់គ្នា នាង គិន-យ៉ាន់ ក៏រៀបស្លាម្លូបារីឲ្យប្ដីដោយ
ផ្ទុកផ្ទន់ ហើយហ្វូនសក្តាក៏លាចុះទូកដោយសារគេ ទៅ
ក្រុងលង្វែក កាលទៅដល់ជិតកំពង់ ក៏នឹកឃើញចិន
សែដែលបានព្យាករណ៍ពីថ្ងៃមុនត្រូវណាស់ ហ្វូនសក្តាក៏
ចូលទូកឡើងទៅឲ្យសិនសែ ទាយព្រះទៅបម នឹង
ព្រះរាជកុមារម្ដងទៀត ។ សិនសែក៏ទាយៈ ព្រោះ
គុនតាំងមាតា នឹងបុត្រយូរបន្តិចហើយ ដែលមិនស្បើយ
ល្ហើយដោយបងប្អូនជួយ តែបើជួយចេញឈ្មោះចំពុំបាន



ទេ បានតែប្រើដោយចំបាយប្រាក់ កាលណារួច
ទោសនឹងមានបុណ្យបារមីខ្ពស់" ។

ហ្វូនសក្តាក៏លាសិនសែ ទៅដល់ក្រុងលង្វែកគំនាប់
មេទ័ពហើយមកផ្ទះឪពុកម្ដាយគមិតាយាយ ចាំងពីរបេះតែយំ
ឲ្យហ្វូនសក្តាជួយដូចម្ដេចនឹងឲ្យទៅបមរួចទោស ហ្វូន
សក្តាក៏សន្ធ្រើនសោកចាំងយប់ថ្ងៃមិនសោយ ទើបស្លូវឪពុក
ម្ដាយកេសាច់ញាតិបងប្អូនខាងគានឹងយាយ ។ ក៏ប្រាប់ថា:
"សាច់ញាតិមានតែអ្នកជំនួញដូញព្រៃគ្មានមុខមន្ត្រីទេ គ្មាន
នរណាទៀតទៅគេសោះ" ។

ហ្វូនសក្តា: "ខ្ញុំបាទបានរកសិនសែទាយម្ដងហើយ
ថាព្រះរាជកុមារនឹងមានបុណ្យបានជាទំណាងព្រះបិតា តែគុន
ខាងដើមនោះឃើញត្រូវបែនផល់ឥឡូវខ្ញុំវិលពីស្រុកមកដល់
ក្ដីពេញជីវិតជំណើនថា ទៅបមជាប់គុក ព្រោះសម្ដេចទៅ
ហ្វាចូលទៅទូលព្រះហ្វូន ខ្ញុំបាទដូចស្លាប់ខ្លួនកណ្ដាលផ្ទះ

ស្ទើរទឹងដើមកញ្ចាទ តែខ្ញុំបាទពុំអស់ចិត្តសោះ លុះមក ដល់កំពង់ល្អងបានឡើងទៅកេសិនសែឲ្យមើលទៀត ” ។

ឥឡូវសិនសែទាយថា “ បើនឹងរួចបានតែបងប្អូនជួយដោយទុកបាយ កុំឲ្យចេញឈ្មោះនាមទើបរួច បានជាខ្ញុំបាទសួរកេបងប្អូន ខាងអ្នកឪពុកប៉ុអ្នកម្ដាយ នឹងឲ្យគេមកជួយកេទុកបាយដូចម្ដេចនឹងដោះឲ្យបាន ខ្លួនខ្ញុំបាទក៏តាល់ប្រាជ្ញានឹងគិតសោះ តែរឿងនេះសុំឲ្យអ្នកឪពុកអ្នកម្ដាយ ទំលាយសេចក្ដីសោកសៅទៅ បើយើងនៅតែចិត្តក្ដុកដូចខ្ទេះ ក៏គាប់អស់ប្រាជ្ញា យាយតាក៏នៅទុក្ខមិនសោយ ។

## វគ្គទី ១៤

ឯសម្ដេចចៅហ្វាក៏ចេះតែនឹកកេទុកបាយដូចម្ដេចឲ្យរួចសក្ដាចេញទៅស្រុកក្រៅ កុំឲ្យនៅស្រុកក្រុងព្រែងបាននឹងពឹង



នឹងជួយទូលពិតដោះទៅឋមមាត ទទួលវេលានោះបះយួន ៗ លើកទ័ពពីស្រុកហើយមកផិតប្រទល់ដែនព្រៃនគរ មានសំបុត្រ លោកអ្នកឧកញ្ញាធារនេះស៊ធាចៅហ្វាយស្រុកខេត្តបាសាក់ ប្ដឹងមកសេនាបតីក្រសួងវេមន្ត្រី ឲ្យយកសេចក្ដីក្រាបទូល ព្រះករុណាសុំលើកទ័ពទៅជួយ ។

ខណៈនោះសម្ដេចចៅហ្វា ក៏អស់សេចក្ដីព្រួយ សប្បាយចិត្តណាស់ នាំយកសេចក្ដីជាហើសទៅក្រាបបង្គំទូល ព្រះករុណា ។ ក៏ពាក់ប្រើឧកញ្ញាពិជ័យសង្គ្រាមមេទ័ពឲ្យលើកពល ១ មុឺន ទៅគន្លឹងទ័ពយួន ចះឯពលជើងគោក ៧ ពាន់ លោកមេទ័ពបាត់ហ្វូងសព្ កាន់កាប់ទ័ពទឹក រើសយកសុទ្ធតែអ្នកចំការមាត់ទន្លេពាំងពីខេត្តសំបុកសម្បូរក្រចេះ ហើយទៅដល់ខេត្តមាត់ជ្រូកក្រមួនសរ ដែលពូកែតែខាងទូក ច្រើនតែពួកការជ្វា លោកមេទ័ពខាងជើងគោកលើកកាត់ខេត្តកេង៉

ទៅព្រៃនគរដល់ផ្ទះរៀផូនណាយ ។

កាលដែលមេចំពួនលើកមក ក៏បានបញ្ចាំងគ្នាជាពន្លឹក សន្លឹកសន្លាប់ខាងចំពៅខ្មែរឈ្នះ ព្រោះជារដូវខែប្រាំង យួនមិនសូវប៉ិនបញ្ចាំងខាងជើងគោកស្មើនឹងខ្មែរ នៅបញ្ចាំងគ្នា ៦ ខែ បានកបចាប់ចំពួនថយទៅក្រុងហ្វេវិញ មេចំពៅខ្មែរក៏ដាក់យាមល្បាតលាតត្រៃវែល យ៉ាងមាំមួន មកឯចំពង់នៅក្នុងបន្ទាយព្រៃនគរ ។

## វគ្គទី១៥

ហ្វូនសក្តាវុធវិទ្ធិត្រៃ កាន់កាប់ជើងទឹកក្នុងខេត្តបាសាក់ បានដាក់យាមល្បាតលាតត្រៃវែល តាំងពីក្របួនសព្រះ ត្រពាំងតាក់បិទតាក់ប៉ាំង បាក់លើវ តាប់ស្តៅ ពាម កញ្ជារត្រៅ ហូតពាមបាក់ង នឹងកូកុងចល់នឹងកាប់ សែងយ៉ក់ ឯទូកដែលហ្វូនសក្តាជិះឈប់នៅកំពង់ មាត់ព្រែកបាក់លើវ ។



មានថ្ងៃ១ ជាខែសកាលបណ្តាលឲ្យហ្វូនសក្តាអផ្សុកក្នុងចិត្តបង់ដើរទៅមើលភូមិថាន ផ្ទះសម្បែងអ្នកស្រុកក្នុងភូមិបាកលើវ ក៏ដើរទៅចំក្រោយកន្សែផ្ទះនាងបពាតដែលប្តីឈ្មោះប្រលិតជាអ្នកក្លែងឈ្មោះតាំងពីនោក់ ឯប្រលិតនឹងនាងបពាត កាលគេមកពីភូមិប្រាសាទ ខេត្តបន្ទាយមាស ទៅនៅភូមិបាក់លើមុនដំបូង សុំផ្ទះគេនៅដោយសារឈ្មោះនេះមានវិជ្ជាចេះធ្វើជាងទង ជាខ្សែកងចិញ្ចៀនប្រអប់គ្រឿងមាសប្រាក់ អ្នកស្រុកនិយមនាំមកធ្វើជាច្រើនណាស់ ក៏បានថ្លាស់សម្បត្តិទ្រព្យគ្រឿងប់ទៅជាអ្នកមាន បានជាវិជសង់ផ្ទះសម្បែងនោខ្ទមឯងយ៉ាងមាំមួន មានតាំងដីស្រែចំការបង្ហូរសួន មានបាវព្រាវប្រុសស្រីបំរើធ្វើការក្នុងផ្ទះ ក្រៅផ្ទះគុរកុំជុំវិញ ។

ឯហ្វូនសក្តានោះមិញ ក៏មានកិរិយាខុសពីមនុស្សធម្មតា គឺជាអ្នកមានស្នេហ៍តាំ ហើយនឹងវិក្កកបំណាំភ្លៃក

លើសគេ តាំងពីក្មេងទៅវិញ ស្គាល់លាយដៃប្រាកដជា
អក្សរក្រោមនោះក្រោមនេះសរសេរ ឲ្យតែឃើញម្ដងក៏ចាំបាន
ក្អកប៉ិនសំឡេងងឹងតាមខ្លួន ទាយមិនខុសពីចម្ងាយដូចដំ-
ណាច់សសរបញ្ចុះផ្កាងប្រែ ឲ្យលើកដំណាប់បញ្ជេ
មុន ហើយសំឡឹងមើលទើបការលាក់ព្រលឹញលើកដាក់
ប្រចាក់ជាក្រោយ ត្រូវល្មមមិនលុងមិនចង្អៀត គឺចាំង
បេះវិជ្ជាឯទៀត ៗ គ្រប់មុខ បេះដាប់គ្នាក់ចាំងស្នែងទីង
ក្នុកជាក្បាប់បេនា បេះការធ្វើជាងឈើ ជាងក្រឡឹងទីង
វិជ្ជាគ្រូពេទ្យចេតជាងគេ ៗ

ជាធម្មតាទម្លាប់ខ្លួនឈ្មោះនេះ ននដើរទៅណាជិត
ឬឆ្ងាយ តែងស្លៀកពាក់ប្រដាប់ជាចាបានចាំងអស់
តែបើដើរទៅពេលរាជការ រមែងមានគ្រឿងសំលៀកបំ-
ពាក់ ១ យកទៅស្លៀកពាក់គ្របពីលើសម្លៀកចាបានជាដ
រាបនណា ១ ក៏មើលមិនស្គាល់ជាមេចាបាន ហើយមានកាំ



បិតក្ដូច ១ សៀតក្នុងចង្កេះ ។

កាលដើរទៅតាមផ្លូវ ខ្ទីមទីងកន្ទ្រផ្ទះនាងបចាត
ខ្លួលនាងចុះមកពីលើផ្ទះមកឈរបេក្ខាប់ឲ្យបាវព្រាវ ជ្រាយ
ដើរ្វើលាតស់ឡាំខ្ញុំមកូឆាយ និយាយបញ្ចេញសំឡេងពួបួស់ ៗ
ហ្វូនសក្ការដើរតាមផ្លូវ ទៅហួសបន្តិច មិនបានជានឹក
លុះឮសំឡេងដល់ត្រចៀក ចាំជាក់ជាសំឡេងនាងសារិ-
កា សំឡេងនោះពិតគ្រាក់ខ្លួនហ្វូនសក្កាថយមកក្រោយ
១ ព្យាមងើបឡើងសំឡឹងឃើញមុខច្បាស់ជានាងសារិកា ១
កំគកដូចគេក្នុក បែរមុខមកចំហ្វូនសក្កាស្គាល់ច្បាស់ជា
មុខប្ដី ភ័យស្លុតខ្លាចអង្គុយចុះដាក់មុខឈ្ងោកជី ៗ

ហ្វូនសក្កាថា : „ ហើតូនស្រីសារិកានៅទីនេះទេ
ឬ បងទៅច្បាំងអូនស្មាប់ ម្ដេចក្រឡប់មកនៅនេះ ងើប
មុខឡើងមើលគ្នាទៀត ? "

នាងសារិកា ជាស្រីស្នេហ៍ដណាស់ហើសក្រោក

ឡើង សំឡេងមុខហ្វុងសក្កា លើកហត្ថាចង្អុលមុខថា « អ្នកឯងនៅឯណា ម៉េចក៏ហ៊ានហៅថាយើងប្អូន ៗ បងប្អូន ឬប្អូនប្រពន្ធ ឬសហាយស្មន់នឹងគ្នា យើងមិនមែនសារិកាឯណា ឬអ្នកឯងជានរណា »

ហ្វុងថា : « នរណាដែលបងសំឡេងមុខ ញ៉ឹងហើយសារិកាប្រពន្ធបង ៗ បានរៀបការក្រោយសំពះពេញជាប្ដីប្រពន្ធនឹងគ្នា » ។

នាង យី ! អ្នកឯងនៅឯណា បានជាមកហ៊ានថាតែផ្តាសប្ដូរ្ចះយើងកំណើតកើតជានៅស្រុកនេះ តាំងពីដើមដូនជីតាម៉ែឪ យើងឈ្មោះបទាត ប្ដីយើងឈ្មោះព្រលិតប្រាកដណាស់ យើងមិនមែនឈ្មោះសារិកា មិនមែនប្រពន្ធអ្នកពីកាលណា យើងមិនដឹងសោះ ។

ហ្វុង យី ! សារិកា នាងមិនគួរភ្លេចបងសោះកាលនាងនៅជាមួយនឹងបង ៗ ថ្នមថ្នមដូចកែវណាអូន ខ្ញុំបងមិ



នៅទៅប៉ុន្មាន ១ ឆ្នាំ ម្ដេចអូនមិនព្រាំចាំបងសិននឹងចាន់យូរប៉ុន្មាន ម្ដេចហ៊ានគាត់ស្រែងបន្ទូលជានផ្ទះ ប្អូនមិនគិតគូរកំសត់ខ្លះទេឬ ? ។

នាង ណៃហើយបារ៉ាវតាំងអស់គ្នា ឯងត្រូវព្រួតចាប់គាត់នេះ នាំទៅជូនលោកតាផ្ទាឯសាលាខេត្តបាច់ ១ ឯងទៅប្រាប់អ្នកជាងឲ្យមកឥឡូវនេះ បារ៉ាម្នាក់ក៏ស្ទុះហើសឡើងលើផ្ទះស្រែកថា អ្នកជាងអ្នកស្រីឲ្យហៅទៅក្រោយផ្ទះ មានប្រុសម្នាក់គេមកប្រកាន់ថា អ្នកស្រីជាប្រពន្ធគេពីដើម ឯជាងប្រលិតកំពុងតែពិនិត្យផុតលោយមាសធ្វើខ្សែកក៏យស្ទុកបេួតមាសពីដៃ តែបានស្ដាប់ភ្លាមៈ ក៏ស្ទុះលោតពីផ្ទះទៅខាងក្រោយ ឃើញប្រពន្ធកំពុងតែខឹងនឹងឆ្កាដៃ គ្មានន័យនឹកគន់មើលខាងហ្វុងសក្កា លុះទៅដល់ឈរទើមករិយា ទើបក្រឡេកភ្នែកប៉ះ ស្គាល់ច្បាស់ជារូបគុនលិន ជាងប្រលិតក៏ស្ទុះស្មាតើស្បូវថាពី ៗ ។។

ប្រពន្ធមិនទាន់ស្លាប់នៅតែថែមជាចាប់ៗ ១ ចោរព្រៃ
ប្រហែល១០នាក់កាន់ដំបងនិងកាំបិតគ្រប់ដៃរៀងខ្លួនហ៊ុំជុំវិញ
ខ្លួនហ៊ុនសក្កា តែមិនទាន់ហ៊ានទៅជិត ។

ហ៊ុនសក្កាឈរទះបដៃ ញញឹមហើយថា «អ្នក
ឯងកល់គ្នាថា សត្វស្រ្កីនហ៊ុនគល់ស្វាយ កុំអាលមើល
ងាយបង់ចាប់យើងៗ ហានការនិយាយ តែនឹងមនុស្ស
ម្នាក់ពីរនាក់ នាងនេះពិតជាប្រពន្ធយើងពីដើមគេចាប់
មក គាត់ប្រុសដែលឈរនេះឬឈ្មោះប្រលិតជាប្តី ។

ប្រលិតថា៖ «យើងជាប្តីនាងបតាកនេះ មើលអ្នក
ឯងមកប្រហារប្រពន្ធយើង ជាប្រពន្ធអ្នកឯង ចាប់ចង
ទៅ» ឯចោរព្រៃទៅជាមិនហ៊ាន ព្រោះឃើញខ្លួន
ប្រាណហ៊ុនសក្កាខ្ពស់ធំមាំមួន ។

ប្រលិតនិងនាងបតាកនៅតែស្រែកថាឲ្យចាប់ៗ ចាប់
ៗ ចាប់ៗ បណ្តាអ្នកស្រុកផ្អកផ្អើល រត់មក



មើលច្រើនណាស់ ហ៊ុនសក្កា ឃើញដូច្នោះក៏រោះអាវ
ស្រាតសំពត់ខ្លាកញ្ជាក់ដល់ជើង ឯគ្រឿងប្រដាប់សំពត់ទា
ហាន ដែលនៅពាក់ក្នុងក៏លេចឡើង ព្រមទាំងអាវនិងខោ
វែងប្រគត់ក្រវាត់ ខ្សែវែង ស្ពាយធៀង១ ចំហៀង
នៅលើស្មា ទៀតអាវក្រោយក៏មានសញ្ញាដាវរយោល
ចុងដៃអាវមានខិនមាសដែលជា សក្តិជាក់ការពេតន
ដូចសម័យនេះ ទោះ ហើយពួកចោរព្រៃទាំងប៉ុន្មាន
ភ័យស្ទើរគ្មានព្រលឹងទាំងអស់គ្នា ម្នា ម្នាអង្គុយចុះលើក
ដៃប្រណម្យសំពះជុំវិញ ឯបណ្តាកូនតាហានក៏ស្ទុះរត់
ចេញពីទីសំណាក់ មករកហ៊ុនសក្កាម៉ាគ្រៀបគ្រាច្រើន
ណាស់ ហ៊ុនសក្កាឃើញដូច្នោះ ក៏ស្រែកហៅតាហាន
តាមរបៀបហាត់ ។

ទី ១ ជាភាពល តាហានក៏ស្ទុះប្រមូលផ្តុំគ្នាប្រ
ហែល ៦០ នាក់ ៖

ទី ២ វិច្ឆិកា : ហត្ថ ទាហានទាំងអស់លើកដៃផ្ដិតសំពះមេ៖

ទី ៣ វិច្ឆិកា - វុធ ទាហានហូតដាវកាន់ត្រង់ពីមុខ ៖

ទី ៤ បរិ ប.ធ ទាហានព័ទ្ធជុំវិញពីក្រោះ

ទី ៥ ធនូ ៥: ទាហានក៏ចាប់ដឹកដៃប្រលិតនិងបតាក ដើរមុខទាហាន ហ្វូងសក្កាដើរពីខាងខ្នងនឹងទាហាន មុខ ដង្រន់ទៅសាលាខេត្តបាសាក់ ចម្ងាយពីទីនោះ ប្រហែល ៤០០ ម៉ែត្រ ។

ទី ៦ កាលបើទៅដល់ផ្លូវធំ ហ្វូងសក្កាស្រែកឲ្យទា·ហានទៀតថា បញ្ញា បញ្ញា.ប: ទាហានក៏ផ្លាស់ជា ៤ ជួរ ១ សង្កាត់ដើរទៅហើយថា ឯកទោ ឯកទោ ទាហានក៏លើកដាក់ជើងស្មើគ្នាជារបៀប ។

ឯប្រលិតមានទឹកមុខស្លុតភ័យណាស់ តែមកគិតថា កើតជាមនុស្សរស់នឹងស្លាប់ជាសម្បត្តិ របស់ខ្លួនតាមការពុះ



អង់ភ័យបន្តិចដើរទៅ ឯនាងបតាកចិត្តរឹងមិនកក់ស្លុតសោះ ។

កាលទៅដល់សាលាខេត្ត ពួកមន្ត្រីក្នុងសាលា មើលឈរមើលច្រើនណាស់ លោកនាយខេត្តនិងចៅហ្វាយស្រុកសក្តិ ១០ កាន់ស្រែកសួរពីលើកើយមុខថា « រឿងអីលោកក្ដួយមេទ័ពអញ្ជើញឡើងមក?»

ហ្វូងសក្កាឡើងទៅហើយថា, បាទ នាងនេះពីដើមជាកិរិយាខ្ញុំបាទ បានរៀបការក្រយាស់ពះនៅនឹងគ្នាប្រហែលបាន ១ ឆ្នាំ ខ្ញុំបាទចូលទៅធ្វើទាហានឯបន្ទាយលង្វែក ដើរច្បាំងជាង ២ ឆ្នាំ វិលទៅស្រុកឯបន្ទាយមាស ស្រាប់តែបាត់នាងនេះពីផ្ទះ ១ កំភ្លើងឆេះអស់ ,, ។

ខ្ញុំបាទមកធ្វើការក្នុងទីនេះ បានដើរទៅលេងឲ្យស្គាល់ស្រុកគេ ស្រាប់តែប្រទះនាងនេះមកមានប្ដី នៅក្នុងក្រុងណោះ នាងនេះឈ្មោះដើមសារិកា ផ្លាស់ប្រែជាបតាក សហាយឈ្មោះប្រលិត ប្រកែកជាមិន

ស្គាល់ខ្ញុំបាទជាប្ដីសោះ ហើយស្រាប់តែហៅបាវព្រាវ ទីដប្ដីមកហ៊ុមព័ទ្ធគិតចាប់ខ្ញុំបាទ ព្រោះឃើញខ្ញុំបាទដើរ ទៅម្នាក់ឯង ឥឡូវនាំមកសុំឲ្យព្រះតេជព្រះគុណជំនុំជំរះឲ្យ ផង ។

ចៅហ្វាយ " ហើ! អាប្លុកម៉្លេះ រឿងយ៉ាងនេះ មិនដែលឮសោះ មែនខាងលោកក្មួយឬមែនខាងគេឯ ណោះ? " ។

ហ្វ៊ងសក្ដា ' បាទ មែនខាងខ្ញុំបាទ បានជាខ្ញុំ បាទប្ដឹង ឯគេខាងណោះ ប្រគេជព្រះគុណសួរគេចុះ " ។

ចៅហ្វាយ ហៅ ២ នាក់ប្ដីប្រពន្ធនាំគ្នាឡើងមក ចៅក្រមទីងស្នួរ ។ នោះអ្នកទាំង២នាក់ប្ដីប្រពន្ធ ក៏ឡើងទៅ លើសាលា លោកចៅហ្វាយខេត្តក៏ផាត់ឲ្យសុភាតាបុរស កត់បណ្ដឹងហ្វ៊ងសក្ដាជាមុន តាមហេតុដែលមិនសុខចិត្ត ទីងនាងសារីកាដែលត្រូវឈ្មោះជាចាត ហើយគេប



ទៅយកប្រលិតគេធ្វើជាប្ដីក្រោយ ។ សុភាតាបុរសក៏សួរគត់ អស់ចំណាំទោទ ទើបឲ្យជូនស្មៀនបន្ទាល់សាក្សី ហ្វ៊ងសក្ដា ជាសាក្សីគង់មានច្រើនខ្លួន ប៉ុន្តែសុទ្ធតែនៅឯភូមិស្រុកសាច ដែលក្របថ្នាយមាស ទីងការនៅៈហៅប្ដូឲ្យចេញដីកានៅ កោះកំទាំឲ្យយូការ ព្រោះជាចំងាយណាស់ សូមឲ្យ លោកកត់ឲ្យច្បាស់ថាខ្ញុំបាទគ្មានសាក្សី ក្រៅពីខ្លួនខ្ញុំបាទ តែម្ដងទៅចុះ ព្រោះថា បើសាក្សីមកធ្វើយកជួចជាខ្ញុំ បាទដដែលជាដរែល បើថាម្នាក់ហើយ ប្រាកដជារូប នាងសារីកាៗ នៅតែប្រកែកមិនទទួលក៏គង់ឥតយកជាការពុំ បានព្រោះនាងនោះ ផតស្វាកស្នាមក្នុងអវយវៈកងកាយ ឲ្យខុសពីមនុស្សធម្មតា សុភាតាបុរសក៏កត់ត្រា ថា ហ្វ៊ងសក្ដាឥតបន្ទាល់សាក្សីក្រៅពីខ្លួនរបស់ខ្លួនទេ" ។

រួចសុភាតាបុរស ក៏ឲ្យចុះនាមលេខា ហើយឲ្យ ចេញមកក្រៅ រួចហៅនាងបវរកចូលទៅទៀតស្នើរ

នាងឯងឈ្មោះអី អាយុប៉ុន្មាន ឪពុកម្ដាយជីដូនជីតា ឈ្មោះអី កើតនៅស្រុកណា របររកស៊ីធ្វើការអី ជាប្រពន្ធហ្លួងមែនឬទេ?

នាងឆ្លើយថា ខ្ញុំឈ្មោះបូតាត ! អាយុ២៣ឆ្នាំ ឪពុកឈ្មោះម៉ាន់ ម្ដាយឈ្មោះដួង ជីតាឈ្មោះម៉ុង ជីដូនឈ្មោះ ចឹម កំណើតកើតនៅភូមិបាក់លើ ខេត្របាសាក់ រកស៊ីធ្វើជាងចង ខ្ញុំពុំមែនជាប្រពន្ធហ្លួងសង្គា ជាឈ្មោះសារិកាឯណា ខ្ញុំម្ចាស់មិនដឹងទេ ខ្ញុំមិនដែលស្គាល់លោកនេះទេ ទើបនឹងឮលោកថាអម្បាញ់មិញ ខ្ញុំក៏ថាតាមទៅៗ

សុភា នាងឯងហ៊ានសាក្សីបានដឹងឮឃើញឬទេ ?

នាង ចាស សាក្សីអ្នកស្គាល់ខ្ញុំ មានគេដឹងឮឃើញពិតប្រាកដច្រើនណាស់ ឆ្លើយចប់ឲ្យគូសស្នាមដៃស្ដាំ ។

សុភា ឲ្យនាងបូតាតថយមកក្រៅ ហើយហៅប្រ



លិតចូលទៅសួរទៀត នាងបូតាតដើរមកប្រញាប់ខ្សឹបប្រាប់ប្រលិតថា ឲ្យឆ្លើយតាមគ្នា តាឈ្មោះម៉ុង យាយឈ្មោះចឹម ឪពុកឈ្មោះម៉ាន់ ម៉ែឈ្មោះដួង ។

ដែលនាងបូតាតឆ្លើយដូច្នេះ ព្រោះគាត់អ្នកស្រុកជិតខាង សុទ្ធតែទំនុកទុកចិត្តស្ដាប់ពីសម្បត្តិរបស់ខ្លួនបាន ជាឆ្លើយផ្ដេសផ្ដាសឲ្យតែរួចពីមាត់ ហ្លួងសង្គានឹងធ្វើអ្វីបាន ។

ឯប្រលិតក៏ឆ្លើយឲ្យតែរួចពីមាត់ ថាខ្លួនកើតនៅភូមិជើងថ្កូង ខេត្រពេជ្របុរី ជាប្ដីនាងបូតាតបានរៀបការក្រយាសំពះពីកំឡោះក្រមុំ នៅស្រុកបាក់លើ យូរឆ្នាំ ហើយ ឲ្យគូសស្នាមដៃឆ្វេង ។

លោកសុភាតាបុរស កត់បណ្ដឹងហ្លួងសង្គាចោទ ទឹងកត់ចម្លើយ នាងបូតាតនាំងចម្លើយប្រលិតស្របគ្រប់ ហើយ ឲ្យគូក្ដីថយមកក្រៅ ហើយនាំសេចក្ដីកត់ហេតុនោះទៅជូនលោកចៅហ្វាយខេត្ត ហើយជំរាបថា: រឿង

អធិករណ៍នេះមិនព្រួយកៅវ៉ៃទេ នៅតែស៊ើបសាក្សីខាង ចម្លើយទៀត ទីផ្តុំពាក្យគាត់បាន ។

លោកចៅហ្វាយខេត្តសួរសុភា តោខនេះជាបងអី សុភា ? ។

សុភា ប្របាទម្ចាស់ តោខជាបងកញ្ជាមហន្ត តោស ហើយរូបតោខជាអគ្គមន្ត្រីមានបណ្ដាសក្តិ ខុសពីសាមញ្ញជនធម្មតា ព្រះច្បាប់ត្រូវឲ្យតុលាការឃុំចះមួយ ចំបែកគ្នាទៅក្នុងគុក ចាំកាត់សេចក្ដី ។

ហ្វុនសក្ដាថា : ខ្ញុំបាទសុំកុំបាច់ឲ្យតុលាការឃាត់ ឃុំរូបចម្លើយឡើយ សុំឲ្យនៅក្រៅចុះ តែសុំកុំឲ្យបាត់ខ្លួន ។

សុភា តាមរបៀបច្បាប់ បងកញ្ជាមិនឲ្យនៅក្រៅឃុំទេ ។

ហ្វុន ខ្ញុំបាទយល់បងកញ្ជាថាផ្លូវនោះមែនតែចំពោះលើ មនុស្សណាប្រព្រឹត្តបទល្មើសទៅ លើសាធារណៈជនឬលើ



ពសការសាធារណៈឯរូបក្ដីនេះ ចំពោះល្មើសផ្ទាល់ខ្លួនតែលើ ជាមនុស្សម្នាក់ បានខ្ញុំបាទសុំ ។

ចៅហ្វាយ យី ! លោកក្ដួយ ម៉េចក៏ចូលចិត្តសុំឲ្យ គូក្ដីរបស់ខ្លួនស្រាលទោសទៅវិញដូច្នេះ ខាងលោកក្ដួយ សុំឲ្យលើកមិនឲ្យយកសាក្សីខាងក ។ គានសាក្សី បើ លោកឲ្យកៃរងក ។ គន់ទៅស្រុកសាក្សីទៀត ឲ្យធ្វើយសម ខាងក យើងមិនគិតតែទាញប្រៀបគេទៀតឬទេ? ។

ហ្វុន បាទ ការទាញឈ្នះដោយសាក្សីក្រៅ ខ្ញុំបាទមិនយកជាប្រមាណទេ ខ្ញុំបាទចង់តែឲ្យលោកតុ-លាការឃើញដោយសាក្សីចំពោះខ្លួនគូក្ដី តោះបីចម្លើយ ទីរ៉ៅទៅស្រុកសាក្សី ក៏ខ្ញុំបាទមិនព្រួយសោះ ខ្ញុំបាទអរ តែគេរៀប ខ្ញុំបាទទីងបានគ្រង់ ។

ចៅហ្វាយ ឲ្យហៅចម្លើយតាំងពីនាក់ចូលទៅ ហើយថា ឯងជាប់ទោសតោខក្នុងបងកញ្ជាមហន្តទោស

ច្បាប់ត្រូវឃុំខ្លួនក្នុងគុកបំបែកគ្នាទំពំកាត់សេចក្តី តែផ្លូវខាងចោទសុំឲ្យលែងខ្លួនឯងបណ្តោះអាសន្ន ឯងត្រូវរកស្មាតើមាំមួន ឲ្យធានាខ្លួនទាំងពីរនាក់ ហើយវិលទៅផ្ទះសិនចុះ បើឃើញជាការការហៅថ្ងៃណាឲ្យចូលមកឲ្យទាន់កំហិត ។

ប្រលិតនិងនាងចបាក ក៏ជយទៅពឹងស្មាក្តីក្នុងសា-លាមួយរំពេច នាំទៅជួបនឹងលោកចៅហ្វាយនឹងសុភាទៅមុខហ្លួងសក្តា ។

ចៅក្រមសួរស្មាក្តីថា: អ្នកឯងហ៊ានធានាចម្លើយពីរនាក់នេះដែរ ? ស្មាក្តី ប្របាទម្ចាស់ ហ៊ានធានាណាស់ ។

ចៅក្រម អ្នកឯងប្រយ័ត្នកុំឲ្យបាត់ខ្លួន ព្រោះចម្លើយជាប់ចោទជាមជ្ឈិមមហន្តទោស ។

ស្មាក្តី ប្របាទម្ចាស់ កុំព្រួយឲ្យសោះមិនបាត់ទេ។



ចៅក្រម សួរហ្លួងសក្តា ខ្ញុំឆ្ងល់ណាស់នឹងលោក ក្បួយមិនឲ្យឃុំចម្លើយ ?

ហ្លួង បាទ បានជាខ្ញុំបាទមិនឲ្យឃុំខ្លួន ព្រោះនៅជាប់ចិត្តអាណិតនាងនេះខ្លាំងណាស់ កាលនៅជាប្រពន្ធខ្ញុំបាទជ្ដមដូចតែ ទោះបីពេលនេះចិត្តគេប្រែក្រឡះ ហើយ ចិត្តខ្ញុំបាទក៏នៅតែអាណិត ។

ចៅក្រម បើអាណិតម្តេចក៏ប្តឹង ? មិនបណ្តោយឲ្យគ្នាសុខចិត្តនឹងប្តីក្រោយទៅ ។

ហ្លួង បាទ បានជាខ្ញុំបាទប្តឹង ព្រោះគេឆ្លើយទទឹងមិនព្រមទទួលថា ខ្លួនគេជាប្រពន្ធខ្ញុំបាទពីដើម ក៏ដូចជាខ្ញុំបាទមកពោលបង្កាច់ឲ្យគេអាក្រក់ឈ្មោះព្រោះខ្ញុំបាទ ។ ប្តឹងនេះប្រយោជន៍ឲ្យឃើញតែត្រង់មែនឬមិនមែន ប៉ុណ្ណោះទេ ព្រោះខ្ញុំបាទប្រាថ្នាកើតមកជាមនុស្ស ត្រូវសាងសេចក្តីត្រង់ជាប្រមាណ បើនាងនេះទទួលឆ្លើយក្នុងពេល

ដែលខ្ញុំបានជួបសួរដំបូង ដូចចំណាំខ្ញុំបាទ ។ នឹងយក
របស់ទ្រព្យទៅបង់ថៃទុកជាកើតទៀត តែឥឡូវប្ដីនឹងរួបទៅ
ហើយ បើតាំងនេះទេរតែដកយកសំដីមុនពោលបញ្ចូល
សំដីថ្មីទៅវិញក៏មិនពេញការ ។

ចៅក្រម សួរសុភាថា: រឿងនេះនឹងត្រូវធ្វើ
ម្ដេចទៅទៀត ? ។

សុភា ប្រាប់ចម្ចាស់ ត្រូវកោះសាក្សីចម្លើយ
មកសួរបំពេញតាមចម្លើយការទៀត ទើបសម្រេចកាត់
សេចក្ដីបាន ។

ចៅក្រម ប្រាប់ចម្លើយថា អស់សេចក្ដីហើយ
ឯងវិលទៅផ្ទះចុះ ចាំស្ដាប់ដីការហៅ ចម្លើយក៏លា
ចុះទៅ នាងបតាតដើរទៅនឹកស្រណោះសំដីហ្វូងសក្ដា
នឹងឃើញចិត្តគេនៅមានមេត្តា មិនឲ្យឃុំឃាត់ខ្លួន បើ
ប្រសិនចិត្តគេកាច្រក់ ឯងក៏ត្រូវនៅក្នុងគុកទូលវេទនា នឹក



ពីឃើញចិត្តប្ដីនៅល្អជា ក៏យំស្រណោះស្មើរប្រែទុក ។

ប្រលិតសួរថា : « ថ្វីអូនបានជាយំ ? »

បពាត « បាស ខ្ញុំយំអាណិតខ្លួនព្រោះគេធ្វើឲ្យ
ជាប់ឃុំ ពាហានតាំបណ្ដឹកើតអផុតខ្មាសគេណាស់ »

ប្រលិត « ណ្ហើយអូនកុំយំ កុំខ្មាសនរណា
កើតមកជាមនុស្សពលគ្នា រមែងប្រទះទុក្ខលំបាកដូច្នេះ
ហើយ បងខ្ញាចតែចិត្តអូនឯងមិនត្រង់នឹងបង នៅបង
មេត្រីនឹងគេជាប្ដីមុន »

បពាត « បាស បងកុំព្រួយបារម្ភ ខ្ញុំពុំប្រែ
ឲ្យខុសដល់ពីដើមទេ ពេលនេះបើខ្ញុំទៅសុំអង្វរទូលគេ
លើក្បាល ក៏គេមិនទទួលយកខ្ញុំវិញទេ ខ្ញុំស្ដាយណាស់
ព្រោះធ្វើយខុសមុនដំបូង បើទទួលអង្វរនឹងជាតែម្ដងហើយ
ខ្ញុំផង »

ប្រលិត « ខុសទេតិតនោះមិនត្រូវសោះ បើអូនឯង

ឆ្លើយទទួលមិនខ្មាសអ្នកស្រុកអាយទេឬ យើងកៀសមកនៅស្រុកនេះ បានអ្នកប្រាប់គេថា៖ ប្ដីប្រពន្ធពីកំឡោះក្រមុំ ម៉េចក៏ទៅជាប្រពន្ធគេទៅវិញ បងក៏តែខ្មាសគេថាឯងលួចប្រពន្ធគេ និងយកមុខទៅទុកឯណា ,,

ចចាក ចាស បងឯងថាត្រូវហើយ តែត្រូវខ្មីណាស់ ចុះបើថ្ងៃក្រោយគេគេទៅឃើញពិត តើទម្ងន់សេចក្ដីខ្មាសនោះ ឯណាធ្ងន់ជាង ?

ប្រលិត ណ្ហើយកុំគិត ៗ តែទៅនិយាយនឹងអ្នកស្រុកផ្ទះជិតខាងឲ្យគេឆ្លើយឲ្យត្រូវនឹងសំដីយើង អស់ប៉ុន្មានក៏អស់ចុះ ។

ជនទាំងពីរបានទៅដល់ផ្ទះ ក៏សូកសាក្សីផ្ទះជិតខាងឲ្យទទួលឆ្លើយថា ធ្លាប់ដឹងឮ-ឃើញចម្លើយទាំងពីររៀបការយកគ្នាជាប្ដីប្រពន្ធនៅស្រុកបាក់លើវ ពូជគម្បូរខាងស្រី ដីដូនដីតាឪពុកម្ដាយនឹងឈ្មោះត្រូវដូចឆ្លើយចម្លើយ



ទីពីរក៏ឆ្លើយត្រូវថា ស្រុកកំណើតនៅភូមិដើងវែង ខេត្តពេជ្ជរីត្រូវរបៀបគ្នាទាំងអស់ ។

## វគ្គទី១៦

ហ៊ុនសក្កាបានលាចុះពីសាលាខេត្រទៅទូកបន្ទាយទាហាន ឲ្យរើសពួកទាហានដែលចំណាន រេះប្រៀងនិងរេះក្បួន ដេញតាប៉ុគ្គុនិងសាររបៀរ ឲ្យទៅប្រៀងក្រោមដើមស្វាយមុខផ្ទះព្រលិតនាងចចាកមានគ្រែមួយគេធ្វើសម្រាប់ដេកអង្គុយលេង ចាប់ប្រៀងតាំងពីម៉ោង ៨ យប់ទៅដល់ពាក់កណ្ដាលអធ្រាត្រ ឲ្យប្រៀងបទដែលពិរោះស្រណេះស្រណោច អន្ទង់អន្ទាច មានបទជាក់ជាយសិរកោម , បំពេ , នគរពជ និងស្ដេចផ្ទុំជាដើម ។

ឯចំនុកប្រៀង ហ៊ុនសក្កាតែងដូចមានយ៉ ១ ខាងក្រោមនេះ ។

# បទផាត់ជាយសារិកាមេនិងបទឯទៀត

## បទបំពេរព្នាក់

សារិកាកែវអើយ ម្ដេចឡើយមកទំ ខុសពី
ទ្រនំ ដំរីសារិកា ។

ដំបូងយើងស្និទ្ធ ជាគូស្នេហា បានពីរវស្សា
ផតអារម្មណ៍ចាប់ ។

ថ្ងៃយប់គ្រប់យាម បងថ្នមពុំគាប់ ពុំឲ្យព្រួយ
ស្ដាប់ ព្រួយស្ដីស្រីបាន ។

ស្រីបងបងស្និទ្ធ បងឈ្មោះរះកាន រះរួន
មិនស្មាន មិនស្មានគបទៀត ។

គុំខុកក្នុងចិត្ត ក្នុងជឿជាស្មៀត ជាស្នេហ៍
កន្សៀត កន្ទុងសង្ហារ ។

បងថ្នមបមមី កូនស្រីសារិកា ពុំផលស្ដី
ជា កាបាទ្រគោះ ។



ពុំផលពាល់សាច់ ប្របាច់ឲ្យរបោះ ឲ្យឈឺ
ពីព្រោះ ដំណោះប្រកែក ។

សារិកាជាកែវ ក្តីផ្សងឯក បងខ្ចប់កែវ
បែក បំណាក់ក្តាក់ផុះ ។

ថ្នមហើយថ្នមទ្រ ស្មើពពុំជ្រុះ បង់ឲ្យកែវ
លុះ មុតមុះសាស្នា ។

រួមទីពីឆ្នាំ បងចាំព្យាបាល ថ្នមស្រី
សារិកា ជាគូកំសត់ ។

បងលាទៅច្បាំង មិនគាំងសន្ទូក កែបង
បានកត់ កំណត់ហាត់ស្តី ។

ថាហួសលើសឆ្នាំ ត្រូវចាំកុំបី សំគាល់
ផលប្ដី ធីងខ្ញុំគ្រឡប់ ។

ប្រហែលពេលពិត ជីវិតផុតកំពូ ព្រោះ
តាមរឿងចិត ខ្ញុំប់ជាប់ក្សយ ។

ប្រសិនអូនមិន លើកតាល័យ ជារូប
ស្លាប់ថ្ងៃ ស្លាប់យប់ក្តីណា ។
គួរស្មូនកាន់ទុក្ខ ទំនុកកេរ្យ ទំនៀម
ជូនតា អស់ការបីធ្នាំ ។
ម្តេចឡើយស្រីកែវ បេញបែរស្រាំ តាម
ទុកបែរប្រាំ មកតាមបាពិប ។
ធ្វើតាមកញ្ញើរ ក្រពើកាប ម្តេចអូនមិន
ខ្លាច អំណាចកម្មពៀរ ។
មុនស្រីលៃលះ ដុតផ្ទះគ្រឹះហា យកខ្មោច
គេជា គាថាខ្លួនស្រី ។
ឲ្យគេតិចត្យ ពេញពិតភកស្តី ពេញប្អាក់
សាក្សី ជាស្រីកែវស្លាប់ ។
តាំងបងគង់ជឿ ជំនឿចំណាប់ បានជឿ
សំពប់ ប្រដាប់ថ្វាយសង្ឃ ។



បងស្បូត្រយំកិច្ចា បណ្តាញចំណង់ បញ្ជូន
ទៅត្រង់ បញ្ចាន់ទុទ្ធិស ។
ទុតានមានលេស ទុខ្លួសតាមិស ទុខ្ជូណាំស្មើ
ពិស ផ្ទះថ្មកាសី ។
ព្រះឥន្ទទេវតា នៅតាសួគ៌ស្រី ហោះ
ធ្លោះចុះខ្ទី តាបីសារិកា ។
ផប់ដូចដូងផលក្លូណ៍ ខរណះមាតា នាំចិត្តជើផ្លា
ឲ្យក្លាហ័ស ។
ព្រុកនឹកកែវ ចេញពីទូកស្មុះ មកជួបពើបប៉ះ
គូបាស់ស្រស់ថ្វា ។
គូអើយគូកម្ម បងក្តាំប្តេជា ឲ្យកែវគ្យា
គ្រឹះហារីចស្ថាន ។
ហើយនឹងមាតា ឲ្យសប្បាយប្រាណ នាំកែវទៅឋាន
ឲ្យបានតាមនស្ស ។

ស្រាប់តែកែកាត់ បែកបាត់ផុតភ័ស្តុ សារិកាលោស់

គេចពាស់ប្រស់គល់ ។

## បទជាត់ជាយក្លាយ

១ កែកុំភ្លូនជូនសារិកា ដេជ្ឈាគ្រាតទឹកនិមល

បើសារិកាសត្វហាត់ហើរទល់ ជួបផល់ផល់ក្រោយ

ដោយសារស្លាប ។

នេះសារិកាបែងនាងជាមនុស្ស ភគពេមចំពុះដុះដកប

ម្ដេចកំហើរហោះផ្លោះគៀងឆាប អូនមិនស៊ើបបាបស៊ើប

វេក ។

បងនិពសនាងជាងបីផ្ទាំ ចិត្តបងគង់ចាំតោមគុំផារ

ទើបតានេចតើគាក ភាំងសង្គ្រាមប្រាថ្នាគេ ។

ផ្ទៃគោកផ្ទៃទឹកខ្ទូកគ្នងពៅ ដូចផ្គើតកណាប្រាវទៅមក

ផល់កោះមាលះកាជាជ្រោយញក មិនជួនពន្ទកស្រី

ចុស្សបា ។



បើនាងក្មួងឈ្មោះផ្គោះសំខាន់ ដូចមួណាកាន់គ្រហ៊ានយ៉ា

គេមានប្រពារៈកាឡា ពេញទីជីភាឯសោឡូស ។

ខេមិត្តបិតបាំងម្ដ្គាកាយ ឲ្យក្លាយសារពាក្ដយ៉ាងបុរស

នេះអូនសារិកាថ្វាថ្ងៃស្រស់ ទៅគ្រឿងតាំងអស់ស្នោះ

ជាស្រី ។

អូនប្រែតែឈ្មោះប្រែតស្ត្រា រូបជាសារិកាល្អពិសី

ថែបនាំគ្នាតំមិនផុតវើ កានវ៉ឲ្យធ្លាយពីបែបង ។

ត្រឹមស្រុកបាត់លៀវគៀវជាប់គុន ដូចទៅសារខុន

ប៊ុនកខ្វន

តែផល់ស្រុតពេបតោមខ្លួនល្អង ម្ដេចម្ដងគង់គេចមិន

ផាច់គូ ។

ពីស៊ុតសាគបេគាបទៅ ជួបបីស្រីតៅទៅគស៊ូ

ព្រោះនាងជាងបេះបួសភគគ្រូ គ្រិត្យគូម្ហូនេបមួបបាសក ។

សារិកាជាគូមិនស៊ូបង វេះធ្ងង់បាំងជ្រោយវែល

គេធក់ ដូចជាកាគីស្រីគ្មានល្អត់ គាក្រក់តែក្រុមចិន
គន្ធិន ។

ស្រីអើយស្រីស្អួតតែតសុរិយន៍ មោហ៍ល្អទ្រន់
វង្សទេវី ក្រឡាកាគីស្រីល្អគ្រន់ សោភ័ណសោភាព
សម្ងាប់ប្ដី ។

បងតាមសម្ព័នជីងអស់អញ ផាក់ចំសម្លាញ់ពេញ
បេតី អ្នកមាំសំឡុតផុតកេចស្រី សាច់ដូចសំឡីរើវេច ។

កម្មអើយកម្មកេតពីរុធ ល្អងសក្ដារុធកាត់ទឹកលេប
កាត់ត្លួសារិកាផ្សាខ្នាំខ្ទប មិនរេបមិនជាប់បន្ទិចសោះ ។

ស្ដាយអើយសែនស្ដាយកាយអូនស្រី កាយុវៃបប៉ីថ្មី
ទៅស្រស់ សាច់ដូចទេសឯកប៉ែកអរេហ្រាះ បងបានកាន់
កោរអស់ផ្ចាំពីរ ។

ពីកាយម្ដាយទុកផុតឥឡាក់ ពេញផ្ចាក់ស័ក្ដិសម
រូបសាមគ្គី ក្រាបក្បាលសំពះតាស់ប្រជ្ញី វេណីគូកាន់



មានខាន់ស្លា ។

ឃើញមុខយុកមាំទាំកាណិត ក្រែងផ្តិតក្រែកប្រឹថ្វាំងក្លា
បាក់ដួបបមថ្លាក់ផាក់ពេលា វាយផេវវាលាជាទ្រគោះ ។

គេមើបកិច្ចមួនស្នួនដូចបង កែវល្អងគង់ល្អៀងទៀង
ទីងឈ្មោះ បើគេបៃគិតពិតសង្គ្រោះ ផតមោះអស់
ហ្វាងបងជួយអរ ។

តែបងកំាងបានឧកីយ៉ានជីង គេខឹងគង់
ខុសពុគ្រេវ ឆាក់ប្រាំថែបប្រាសច្ចន់លើសបុ អូនក្រ
ឥត្រោះព្រោះនណា ?

សែនអើយសែនក្រួនផ្ញូនកាណិត សាច់អើយសាច់
ល្អិតស្រួចល្អះថ្ងា កែវអើយកែវល្អក្លួសារិកា កម្មអើយកម្ម
អភ័ព្វរូបស្រី ។

ឲ្យជាវិកចកើតទុបសគ្គ ពេញថ្នាក់ទ្រកៅផិតស្វាមី
បងទោចអូនធ្វើយស្បើយបេត្រី យើងក្តីកែក្ដីស្រីកុំក្តៅ ។

កស្រ័យឃ្មុំថ្ងៃថោកមកពីថ្ងង    ដំណឹងដំណើរលើលោកទៅ
ក្រមពិតយុត្តិធម៌ល្អក្នុងក្រៅ    ទើបប្រាជ្ញគាប់ហៅតុលាការៗ
ប្រសិនមិនត្រង់ក្នុងផ្ដុំហិរ    យើងត្រូវខ្ទួរណិសាទ្ធកាញ្ជ
បើសាទ្ធមិនហើសក្សត្រា    ភយរនដឹកាថ្នាយកាត់អើយៗ



កាលពួកចៅប្រៀនក្មេង ប្រៀនលេងនៅមុខផ្ទះតាងចពាក ទឹងព្រលិត  តាងនេះបានឮក្មេងទាំងអស់ប៉ប្រៀនផ្ទះផ្ដងចំ ទងលើរៀនខ្លួនផ្ទះ  ក៏ឲ្យផុតផុសស្ទើរនឹងប្រែះក្លាយតក ឲ្យមានចិត្តគិតក្តៅផ្សាទីងកម្មខ្លួនដែលប្រព្រឹត្តខុសមកជួបទីង ប្រុសឯក្រោយ  ជាមនុស្សមិនចេះថ្លមស្រីដូចថ្ពីមុនបានតែ ដេរជេយេកទោសជាគុណ ១  ជាទោសលើសលុប ដូច ពេលថ្ងៃយប់ប្រលោ្ហះតាស់ផែនគ្នា  ដេរជេយដំប្រំបាក់ ហួសជាក់អ្នកល្អ  តាងចពាកក័កក់ពយំសោកាកល័យ ហ្វូងសក្កា  ពន់ប្រមាណណាសាំតែឥតលុះទីងរិះគិតបពណា ព្រោះដើរព្យាស់ជាហ្វូងសក្កាមិនត្រូវការការទ្យារកាល័យខ្លួន ក្រាំងតែបំរកឲ្យកឲ្យអៀនខ្មាស  រៀនដែលដើងក្នុងពកាស ដែលខ្លួនហាងៗបាយហើងណា  ក៏គឺព្រាជ្ញាចេះរិះគិតហ្វូង សក្កាឯង  ឆានដើងជាមនុស្សនេះ  តាំងប្រាក្ស្នធ្នាកប្រើន

ណាស់ ព្រោះតាពុកប្រាប់ ។

ក្នុងពេលយប់នោះ នាងបពាតចេះតែអង្គុយយំជិតក្លី មិនដេកសោះព្រលិតឃើញដូច្នោះចេះតែលោមសួរ នាងនេះក៏ប្រាប់ត្រង់ថាយំអាណិតខ្លួន ព្រោះគិតខុស មិនបានប្រាប់សព្វសុះត្រង់ប្តីក្រោយដែរ ព្រលិតក៏ពាល់និយាយ គ្រាន់តែលោមនាងថាកុំយំកម្មយើងទេ ។

លុះព្រឹកឡើងមានបំរើពីសាលាខែត្រឲ្យទៅហៅយកសាក្សីបាន ៨ នាក់នាំទៅសាលាសុភាតាបុរសគឺសួរសាក្សីទាំងនោះ តាមរបៀបច្បាប់ សាក្សីទាំងអស់ឆ្លើយដូចការតាមលំដាប់គ្រប់ ៗ គ្នា ត្រូវតាមពាក្យដែលចម្លើយបន្ទាប់ ។

## កាត់សេចក្តី

– លោកចៅហ្វាយស្រុក ខែត្របាសាក់ជាអធិបតី

– សភាស្តាំតាបុរស ជាចៅក្រម



– សុភាឆ្វេងតាបុរស ” ”

– យោកក្បាត់ ជាក្រឡាបញ្ជី

បានជួបជុំពិភាក្សា រឿងហ្នុងសក្តាវុធវិថ្លៃក្រមេច័តជើងទឹកទោទ

នាងបពាតទី ១ }
ឈ្មោះព្រលិតទី ២ } . . ជាចុងចម្លើយ

## ករណីយប្តីប្រពន្ធផិតក្បត់ បទអាជ្ញាជាមជ្ឈិម

ទោទជាចម្លើយទី ១ ជាភរិយាដើមឈ្មោះនាងសារិកាកែវឈ្មោះជាបពាត មកយកចម្លើយទី ២ ធ្វើស្វាមីក្រោយ ហើយគេពីទីលំនៅ ១ ភូមិប្រាសាទ ខែត្របន្ទាយមាស មកនៅភូមិបាក់លើ ខែត្របាសាក់ ហេតុដែលចម្លើយប្រព្រឹត្តដូច្នេះបាន ព្រោះទោទមិននៅ ទៅច្បាំងដែរង ១ ឆ្នាំ ទើបវិលមកវិញ ស្រាប់តែបាត់ចម្លើយ

ទើបមកជួបនៅទីនេះ បានប្រកាន់ ចម្លើយ ។ ប្រកែកបដិសេធមិនទទួលថាជាឈ្មោះនាងសារិកា នឹងមិនទទួលថាជាភរិយាពោធសោះ ជាខ្លួនឈ្មោះបេតាត ស្វាមីឈ្មោះព្រលិតទៅវិញ ។

ពាក្យចម្លើយឆ្លើយតប្រកែកដូចពុំងពាក្យពោធមែន ហើយថែមជាខ្លួនចម្លើយមានត្រកូលជីដូនជីតាម៉ែឪនៅស្រុកនេះ កើតនឹងរៀបការយកគ្នាធ្វើប្តីប្រពន្ធនៅស្រុកនេះ ។

## បានបញ្ជាក់ដល់សួរបន្ទាល់ សាក្សី

ពោធថាគ្មានសាក្សីក្រៅពីខ្លួនរបស់ខ្លួនទេ គឺខ្លួនពោធជាសាក្សីឯងចម្លើយណាងមានសាក្សី ៨ នាក់មកសួរ ឆ្លើយសមប្រកបនឹងចម្លើយណាង ។

## ដាងហ្វាងសួរបញ្ជាក់ពោធទៀត

ដាងហ្វាង — "លោកក្តីយកណាងខ្លួនឯងជាសាក្សីនោះ គឺកេងក្រុះនឹងស្គាល់ចម្លើយទី ១ ជាភរិយានោះ គឺ



ស្គាល់អ្វីជាជាក់លាក់ជាងគេ ?"

ហ្វួន — "បាទ, សូមជំរាបព្រះតេជព្រះគុណខ្ញុំបាទកេងស្មារតី នឹងភ្នែករបស់ខ្ញុំបាទ ជាទីចាំហើយនឹងទីស្គាល់ ជាប្រាកដជាចម្លើយទី ១ ពីដើមឈ្មោះនាងសារិកាជាភរិយាខ្ញុំបាទ ឯលក្ខណៈចម្លើយដែលនៅឲ្យខ្ញុំបាទចាំនឹងស្គាល់បានមាន ១០ សណ្ឋាន ៖

ទី ១ ស្គាល់ របៀបសក់
ទី ២ ,, វង់មុខ
ទី ៣ ,, វង់ចិញ្ចើម
ទី ៤ ,, វង់ភ្នែក
ទី ៥ ,, ត្រង់ស្លឹកត្រចៀកនឹងច្រមុះ
ទី ៦ ,, ផ្ទះមាត់នឹងបបូរមាត់លើក្រោម
ទី ៧ ,, របៀបធ្មេញ
ទី ៨ ,, ចាំសំដីដែលស្តីនិយាយ

ទី ៩ ,, ទ្រង់ទ្រាយដងខ្លួនមិនសម្បុរខ្លួនទាំងអស់

ទី ១០ ,, ដំណើរដើរនិងជំហរអត្តិយ

ទាំង ១០ សណ្ឋាននេះ នៅដូចចំណាំពីដើមតំ ខុសសោះ ខ្ញុំបាទសូមអធិប្បាយជូនឲ្យជ្រាបថា រូបមនុស្ស ដែលកើតមកក្នុងលោកនេះ មិនមែនដូចគ្នាទាំងអស់ទេ ហេតុដែលមិនដូចព្រោះគុណចិត្តដើមមិនដូចគ្នា មិនមែនតែ នគរកម្ពុជារបស់យើងដែលរូបមនុស្សកើតជាងគេទេ សូម្បី ប្រទេសធំៗ មានមនុស្សដល់រាយពាន់លានក៏មិនមានរូប មនុស្សដូចគ្នា បើដូចក៏ដូចមិនសព្វគ្រប់ក្នុង ១០ សណ្ឋាន ដែរ បើដូចយ៉ាងច្រើនបំផុតក៏ត្រឹមតែ ៤ ឬ ៦ សណ្ឋាន តែបើមនុស្សមិនចេះសង្កេតគន់ថាដូចគ្នាបានខ្លះ ឬក្រឡេក ឃើញរហ័សហើយហួសទៅក៏នៅថាដូចបាន តែមិនមែន ដូចទាំងអស់ មនុស្សក្នុងគ្រួសារបានខ្លះដូចគ្នាមើលមិនស្គាល់ ថាណាជាណា តែគង់មានអាការឯណាមួយឲ្យខុស លុះ



តែចេះសង្កេតទើបដឹងច្បាស់ជាមានមិនដូចគ្នា ។

តាំងហ្វាង-ឆ្លើយតបថា៖ "លោកក្ឃយ ថានោះមិនពិត ត្រូវអស់ទេ សត្វបក្សីមានក្អែកទឹកឆឹងស្មោញជាដើម នរណាថាមិនដូចគ្នាខ្ញុំមិនជឿទេ ព្រោះខ្ញុំយល់ថាដូចគ្នា,, ។

ហ្វុង– "បាទ" ព្រះតេជព្រះគុណយល់ថាសត្វនោះដូចគ្នា តែលោកដែលឃើញវាឈ្មោះប្រចាំគ្នាដែរឬទេ ?

តាំងហ្វាង ខ្ញុំដែលឃើញដែរលោកក្ឃយ ។

ហ្វុង– "បាទ" ហ្នឹងហើយមិនដូចគ្នា ធម្មតាសត្វមានចិត្តប្រព័ន្ធញី ឈ្មោលលើសចិត្តមនុស្ស កាលចេញទៅរកស៊ីដើរច្រឡំគ្នា តែកាលដេកវាមានគូវាដកប វាមិនយកគូគេមកធ្វើគូឯងបានទេ ដែលវាស្គាល់គូវាបានព្រោះមានចំណាំតាមភាសាសត្វ យើងមិនស្គាល់តាមវាមិនបានដូចចះប៉ុយម៉ី ១ ប្រាកដជាគយោខ្ញុំបាទចាប់ចំណាំបាន ។

## តុលាការបួលជំនុំស្វាត់ចេញកាត់សេចក្តី